ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ច្បាប់

# ស្តីពី

# របបសារព័ត៌មាន

ឆ្នាំ១៩៩៥

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

នស/រកម/០៨៩៥/០៧

# ព្រះរាជក្រម

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍ និករោត្តម**

**ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

******

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានទ្រង់យល់ព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ ចុះថ្ងៃទី២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួល សមាសភាព រាជរដ្ឋាភិបាលកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំអំពីសម្តេចនាយករដ្ឋមន្ត្រីទាំងពីរ នឹង រដ្ឋមន្ត្រី ក្រសួងពត៌មាន

# ប្រកាសឱ្យប្រើ

ច្បាប់ដែលបានអនុម័តដោយរដ្ឋសភា នៅថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ១៩៩៥ ស្តីពី របបសារពត៌មាន ដែលមានសេចក្តីទាំងស្រុងដូចតទៅ :

# ច្បាប់
# ស្តីពី
# របបសារព័ត៌មាន

## ជំពូកទី១
## សិទ្ធិ និង សេរីភាពខាងសារព័ត៌មាន

**មាត្រា១.-**

ច្បាប់នេះកំណត់របបសារព័ត៌មាន និងធានារ៉ាប់រងសេរីភាពសារព័ត៌មាន និងសេរីភាពខាងការបោះពុម្ពផ្សាយឱ្យបានសមស្របតាមមាត្រា៣១ និងមាត្រា៤១ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា២.-**

សារព័ត៌មានមានសិទ្ធិរក្សាការសម្ងាត់ស្តីពីប្រភពព័ត៌មានរបស់ខ្លួន ។

**មាត្រា៣.-**

ដើម្បីរក្សាឯករាជ្យនៃសារព័ត៌មាន ការត្រួតពិនិត្យមុនពេលបោះពុម្ពផ្សាយត្រូវហាមឃាត់ ។

**មាត្រា៤.-**

ការបោះពុម្ពផ្សាយនូវព័ត៌មានផ្លូវការ ដូចជា សេចក្តីថ្លែងការណ៍ ការប្រជុំ កំណត់ហេតុប្រជុំ ឬរបាយការណ៍ណាមួយ ។ល។ មិនអាចត្រូវផ្តន្ទាទោសបានឡើយ ប្រសិនបើការផ្សាយនោះមានលក្ខណៈសមស្របតាមសភាពពិតពេញលេញ ឬសេចក្តីសង្ខេបត្រឹមត្រូវតាមរឿងពិត ។

ព័ត៌មានផ្លូវការដែលជាកម្មវត្ថុនៃមាត្រានេះសំដៅចំពោះ :

១-សេចក្តីថ្លែងការណ៍ ការប្រជុំ កំណត់ហេតុប្រជុំ ឬរបាយការណ៍របស់រដ្ឋសភា រាប់ទាំង គណៈកម្មាធិការ ឬគណៈកម្មការនានារបស់រដ្ឋសភាផង លើកលែងតែក្នុងករណីរដ្ឋសភាធ្វើការប្រជុំសម្ងាត់ ដូចមានចែងក្នុងមាត្រា៨៨ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ។

២-សេចក្តីថ្លែងការណ៍ ការប្រជុំ កំណត់ហេតុប្រជុំ ឬរបាយការណ៍នៃផ្នែកនីតិប្រតិបត្តិ រួមទាំងសេចក្តីថ្លែងការណ៍របស់រដ្ឋមន្ត្រី និងមន្ត្រីនានាផង ។

៣-គ្រប់ទិដ្ឋភាពនៃដំណើរការរបស់តុលាការ រាប់ទាំងនីតិវិធីទាំងឡាយផង លើកលែងតែក្នុងករណីដូចខាងក្រោមនេះ :

-តុលាការហាមមិនឱ្យបើកចំហដល់សាធារណជន

-បញ្ញត្តិដោយមាត្រា១៦នៃច្បាប់នេះ ដែលទាក់ទងទៅនឹងអាថិកំបាំងរបស់បុគ្គលម្នាក់ៗនៅក្នុងដំណើរការជំនុំជម្រះក្តី

-សំណុំរឿងដែលនៅក្នុងការអង្កេតស៊ើបសួររបស់តុលាការនៅឡើយ ។

**មាត្រា៥.**

១-គោលការណ៍ទូទៅ

សារព័ត៌មានមានសិទ្ធិទទួលព័ត៌មានដែលឋិតក្នុងការគ្រប់គ្រងរបស់រាជរដ្ឋាភិបាល លើកលែងតែព័ត៌មានណាដែលបណ្តាលឱ្យ :

-អន្តរាយដល់សន្តិសុខជាតិ

-អន្តរាយដល់ទំនាក់ទំនងជាមួយប្រទេសដទៃ

-មានការបំពានលើសិទ្ធិរបស់បុគ្គលម្នាក់ៗ ដោយរាប់ទាំងសំណុំរឿងរបស់មន្ត្រីរាជការ សំណុំរឿងពេទ្យ សំណុំរឿង និងឯកសារផ្លូវការសម្ងាត់ៗដទៃទៀត ជាដើម

-មានការលាតត្រដាងឯកសារសម្ងាត់ផ្នែកពាណិជ្ជកម្ម ផ្នែកហិរញ្ញវត្ថុដែលបានមកពីបុគ្គល ឬអង្គភាពត្រឹមត្រូវតាមច្បាប់ណាមួយ និងការលាតត្រដាងនូវព័ត៌មានដែលពាក់ព័ន្ធទៅនឹងបទបញ្ជា ឬការត្រួតពិនិត្យរបស់ស្ថាប័នហិរញ្ញវត្ថុ

-ប៉ះពាល់ដល់សិទ្ធិជនណាម្នាក់ក្នុងការនាំឱ្យមានជំនុំជម្រះក្តីដោយអយុត្តិធម៌

-មានគ្រោះថ្នាក់ដល់មន្ត្រីដែលត្រូវអនុវត្តន៍ច្បាប់ ឬត្រូវបំពេញបេសកកម្មរបស់ខ្លួន ។

២-ការស្នើសុំព័ត៌មាន

ការស្នើសុំព័ត៌មានត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ ហើយត្រូវបញ្ជាក់ឱ្យបានច្បាស់លាស់អំពីព័ត៌មានដែលស្នើសុំទៅស្ថាប័ននានា ។

មន្ត្រីមានសមត្ថកិច្ចដែលគ្រប់គ្រងស្ថាប័ននោះ ត្រូវឆ្លើយតបទៅនឹងពាក្យសុំក្នុងរយៈពេលសាមសិប (៣០) ថ្ងៃយ៉ាងយូរ ។ ប្រសិនបើការស្នើសុំនោះត្រូវបានបដិសេធទាំងស្រុង ឬខ្លះៗនោះ ហេតុផលនៃការបដិសេធត្រូវបញ្ជាក់ឱ្យបានច្បាស់លាស់ជាលក្ខណ៍អក្សរ ។

## ជំពូកទី២
## ការទទួលខុសត្រូវនៃអ្នកសារព័ត៌មាន

**មាត្រា៦.**

អ្នកសារព័ត៌មានមានសិទ្ធិបង្កើតសមាគមអ្នកសារព័ត៌មាន ។ សមាគមអ្នកសារព័ត៌មាននោះត្រូវមានលក្ខណៈឯករាជ្យ ។សមាគមអ្នកសារព័ត៌មាននីមួយៗត្រូវអនុម័តលក្ខន្តិកៈរបស់ខ្លួន ដែលមិនផ្ទុយនឹងច្បាប់ជាធរមានដោយមានការយល់ព្រមពីសមាជិកតាមការបោះឆ្នោត ។ អ្នកដឹកនាំសមាគមអ្នកសារព័ត៌មានដែលជាសមាជិកក្រុមអភិបាល ត្រូវមានការបោះឆ្នោតជ្រើសរើសតាមលក្ខណៈប្រជាធិបតេយ្យ ។

**មាត្រា៧.**

សមាគមអ្នកសារព័ត៌មាននីមួយៗត្រូវតាក់តែងក្រមសីលធម៌ដើម្បីអនុវត្តន៍ក្នុងសមាគមរបស់ខ្លួន ដែលអ្នកសារព័ត៌មានមានកាតព្វកិច្ចគោរពគោលការណ៍ចាំបាច់ ជាអាទិ៍ដូចតទៅ :

១-គោរពសច្ចធម៌ និងគោរពសិទ្ធិយល់ដឹងនូវសច្ចធម៌របស់សាធារណជន ។

២-ត្រូវផ្សាយនូវដំណឹងទាំងឡាយដោយសុចរិត ព្រមទាំងធ្វើអត្ថាធិប្បាយ ឬរិះគន់ឱ្យត្រឹមត្រូវ និងសម

ស្របតាមគតិយុត្តិធម៌ ។

៣-ត្រូវរាយការណ៍តែតាមហេតុការណ៍ដែលខ្លួនដឹងពីប្រភពដើមតែប៉ុណ្ណោះ ។ អ្នកសារព័ត៌មានមិនត្រូវបំបាត់ចោលនូវព័ត៌មានសំខាន់ៗ ឬកែបន្លំឯកសារផ្សេងៗឡើយ ។

៤-ប្រើវិធីសុចរិតត្រឹមត្រូវដើម្បីស្វែងរកដំណឹង រូបថត និងឯកសារផ្សេងៗ ។

៥-ត្រូវធ្វើការកែតម្រូវនូវព័ត៌មានណាដែលចេញផ្សាយរួចហើយៗមានលក្ខណៈមិនជាក់លាក់ និងនាំឱ្យមានការយល់ច្រឡំ ។

៦-ត្រូវជៀសវាងការផ្សព្វផ្សាយព័ត៌មានដែលញុះញង់ឱ្យមានការប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿ សាសនា មតិ ឬនិន្នាការនយោបាយ ដើមកំណើតជាតិ ឋានៈសង្គម ធនធាន ឬស្ថានភាពដទៃទៀត ។

៧-ត្រូវគោរពសិទ្ធិ និងសេរីភាពរស់នៅក្នុងជីវភាពឯកជនរបស់បុគ្គល ។

៨-ត្រូវគោរពឱ្យបានម៉ត់ចត់តាមក្បួនវេយ្យាករណ៍ខ្មែរក្នុងការសរសេរអត្ថបទ ។

៩-ហាមបោះពុម្ពផ្សាយអត្ថបទ ឬរូបភាពអាសអាភាស និងរូបភាពនៃអំពើហិង្សា ។

១០-ហាមរំលោភលើសិទ្ធិដើម្បីមានការជំនុំជម្រះក្ដីដោយយុត្តិធម៌របស់បុគ្គលម្នាក់ៗ ដូចមានចែងក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ។

១១-ត្រូវចាត់ទុកចំណុចដូចខាងក្រោមនេះជាការរំលោភដ៏ធ្ងន់ធ្ងរខាងផ្នែកវិជ្ជាជីវៈរបស់អ្នកសារព័ត៌មាន :

-ការលួចចម្លងគំនិត ឬស្នាដៃរបស់អ្នកដទៃមកដាក់ថា ជារបស់ខ្លួន

-បន្លំឱ្យគេយល់ខុស ដូចជាការសរសេរបញ្ឆិតបញ្ឆៀង ដើម្បីឱ្យអ្នកអានមានការសង្ស័យដោយអយុត្តិធម៌លើបុគ្គលណាម្នាក់ ក្រុម បក្សណាមួយ

-ការមួលបង្កាច់ បរិហារកេរ្តិ៍ និងការជេរប្រមាថ

-ការទទួលសំណូកក្នុងបែបណាមួយ ឬការជំរិតយកប្រាក់ ដើម្បីជាថ្នូរនឹងការបោះពុម្ពផ្សាយ ឬមិនបោះពុម្ពផ្សាយនូវព័ត៌មានណាមួយ ។

**មាត្រា៨.-**

មុនពេលចាប់ផ្ដើមចែកចាយសារព័ត៌មាន និយោជក ឬនិពន្ធនាយកត្រូវធ្វើពាក្យមួយ(០១)ច្បាប់ជូនមកក្រសួងព័ត៌មាន ដើម្បីបញ្ជាក់អំពីអត្តសញ្ញាណរបស់ខ្លួន ។ ក្រសួងនេះត្រូវចេញបង្កាន់ដៃឱ្យទៅសារព័ត៌មានពេលបានទទួលសំណុំបែបបទទាំងមូល ។

ក្នុងករណីដែលនាយកការផ្សាយជាសមាជិករដ្ឋសភា ឬស្ថាប័នដែលមានអភ័យឯកសិទ្ធិ សារព័ត៌មាននោះត្រូវចាត់តាំងឱ្យមានសហនាយកការផ្សាយម្នាក់ទៀត ។

និយោជក ឬនិពន្ធនាយកដែលមិនគោរពបែបបទនេះជាមុន ត្រូវផ្ដន្ទាទោសពិន័យជាប្រាក់ពីប្រាំសែន(៥០០.០០០)រៀល ទៅមួយលានប្រាំសែន(១.៥០០.០០០)រៀល ។ ក្នុងករណីមិនរាងចាល ត្រូវពិន័យជាប្រាក់ទ្វេឡើង ។

**មាត្រា៩.-**

សំណុំបែបបទដែលនិយោជក ឬនិពន្ធនាយកត្រូវបំពេញមានជាអាទិ៍ :

-អត្តសញ្ញាណប័ណ្ណនៃសារព័ត៌មាន

-ឈ្មោះ និងអាសយដ្ឋានរបស់និយោជក ឬនិពន្ធនាយក

-ឈ្មោះ និងអាសយដ្ឋានរបស់រោងពុម្ព

-លិខិតថ្កោលទោស

រាល់ការផ្លាស់ប្តូរព័ត៌មានខាងលើនេះ ត្រូវជូនដំណឹងទៅក្រសួងព័ត៌មានប្រាំ(៥)ថ្ងៃមុន លើកលែងតែករណីប្រធានស័ក្តិ ។

**មាត្រា១០.-**

ជនណាម្នាក់ដែលយល់ថា អត្ថបទណាមួយទោះជាសរសេរបញ្ចិតបញ្ចៀងក៏ដោយ រូបគំនូរ ឬរូបថតណាមួយនៃសារព័ត៌មានណាមួយដែលមានលក្ខណៈខុសពីការពិត ធ្វើឱ្យខូចខាតដល់កិត្តិយស និងសេចក្តីថ្លៃថ្នូររបស់ខ្លួន មានសិទ្ធិទាមទារឱ្យសារព័ត៌មាននោះធ្វើការកែតម្រូវ ឬមានសិទ្ធិឆ្លើយតប និងធ្វើបណ្តឹងពីបទបរិហារកេរ្តិ៍ ពីបទមួលបង្កាច់ ឬពីបទជេរប្រមាថចំពោះការប៉ះពាល់កិត្តិយស និងសេចក្តីថ្លៃថ្នូររបស់ខ្លួន ។ ចម្លើយកែតម្រូវ ឬឆ្លើយតបត្រូវចុះផ្សាយក្នុងរយៈពេលប្រាំពីរ(៧)ថ្ងៃយ៉ាងយូរ ឬនៅលេខបន្ទាប់ក្រោយពីបានទទួលការទាមទារឱ្យកែតម្រូវឬឆ្លើយតប ។

ចំពោះករណីដែលពាក់ព័ន្ធដល់បុគ្គលសាធារណៈ គ្រប់ការពោលអះអាង ឬការទម្លាក់កំហុសដែលអ្នកសារព័ត៌មានយកមកចុះផ្សាយដោយផ្ទាល់ ឬក៏យកមកចុះផ្សាយបន្តខុសពីការពិត ក្នុងបំណងបំផ្លាញបុគ្គលសាធារណៈនោះ គឺជាការមួលបង្កាច់ដែលច្បាប់ហាមឃាត់ ។

បើតុលាការរកឃើញថា ការផ្សាយណាមានលក្ខណៈខុសពីការពិតតាមបណ្តឹងរបស់ដើមបណ្តឹងរដ្ឋប្បវេណី តុលាការអាចបង្គាប់ឱ្យសារព័ត៌មាននោះ :

-ចុះផ្សាយនូវការកែតម្រូវ ឬ

-សងជំងឺចិត្ត ឬ

-ចុះផ្សាយនូវការកែតម្រូវផង និងបង់ប្រាក់សងជំងឺចិត្តផង ។

អត្ថបទកែតម្រូវដែលអ្នកសារព័ត៌មានមានកាតព្វកិច្ចផ្សាយ ត្រូវចុះផ្សាយនៅទំព័រដូចគ្នា និងមានទំហំអក្សរប៉ុនគ្នានិងអត្ថបទដែលបានចាត់ទុកថា ជាអត្ថបទធ្វើឱ្យខូចខាតកិត្តិយស និងសេចក្តីថ្លៃថ្នូររបស់គេ ។

លើសពីនេះ តុលាការអាចផ្តន្ទាទោសពិន័យជាប្រាក់ពីមួយលាន(១.០០០.០០០)រៀល ទៅប្រាំលាន(៥.០០០.០០០)រៀល ទៀតក៏បាន ។

ម្យ៉ាងទៀត ក្នុងករណីដែលមានការវិនិច្ឆ័យអំពីអំពើណាមួយដែលមានចែងក្នុងកថាខណ្ឌខាងលើ តុលាការអាចបញ្ជាឱ្យបិទផ្សាយសេចក្តីសម្រេចរបស់ខ្លួននៅទីកន្លែងទាំងឡាយដែលតុលាការនឹងបញ្ជាក់ ដោយឱ្យជនជាប់ចោទទទួលបន្ទុកចេញសោហ៊ុយ ហើយតុលាការអាចចុះផ្សាយសាលក្រមនេះក្នុងសារព័ត៌មានមួយ ឬច្រើន និងឱ្យជនជាប់ចោទទទួលបន្ទុកចេញសោហ៊ុយទាំងអស់ ដោយកម្រិតត្រឹមមួយលាន(១.០០០.០០០)រៀលយ៉ាងច្រើនបំផុត ។

**មាត្រា១១.-**

សារព័ត៌មានមិនត្រូវបោះពុម្ពផ្សាយនូវអ្វីដែលនាំឱ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ ដោយញុះញង់ដោយផ្ទាល់ឱ្យមនុស្សម្នាក់ ឬច្រើននាក់ប្រព្រឹត្តអំពើហិង្សា ។

ការប្រព្រឹត្តបទល្មើសដែលមានចែងខាងលើនេះ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពីមួយលាន(១.០០០.០០០)រៀល ទៅប្រាំលាន(៥.០០០.០០០)រៀល ។

បុគ្គលរងគ្រោះដោយអំពើខាងលើ មានសិទ្ធិតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីទៅតុលាការ ។

គ្រប់ករណីទាំងអស់ តុលាការត្រូវពិនិត្យទៅលើទំនាក់ទំនងដោយផ្ទាល់រវាងអត្ថបទញុះញង់នឹងអំពើនោះ ។ អត្ថបទដែលមានចំណាស់លើសពីបី(៣)ខែ មិនអាចយកមកសំអាងក្នុងការចោទប្រកាន់បានឡើយ ។

**មាត្រា១២.-**

សារព័ត៌មានមិនត្រូវបោះពុម្ពផ្សាយ ឬផ្សាយបន្តនូវព័ត៌មានដែលបណ្តាលឱ្យប៉ះពាល់ដល់សន្តិសុខជាតិ និងស្ថិរភាពនយោបាយ ។

និយោជក និពន្ធនាយក ឬអ្នកនិពន្ធអត្ថបទ អាចត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពីប្រាំលាន(៥.០០០.០០០) រៀល ទៅដប់ប្រាំលាន(១៥.០០០.០០០)រៀល ដោយមិនទាន់គិតដល់ការផ្តន្ទាទោសតាមច្បាប់ព្រហ្មទណ្ឌ ។

ក្រសួងព័ត៌មាន និងក្រសួងមហាផ្ទៃមានសិទ្ធិប្រមូលយកអត្ថបទល្មើស និងសារព័ត៌មានលេខចេញផ្សាយអត្ថបទល្មើសដែលចេញផ្សាយដោយសារព័ត៌មាននោះ ។ ក្រសួងព័ត៌មានមានសិទ្ធិផ្អាកការផ្សាយក្នុងរយៈពេលមិនហួសពីសាមសិប(៣០)ថ្ងៃ ហើយបញ្ជូនសំណុំរឿងទៅតុលាការ ។

**មាត្រា១៣.-**

សារព័ត៌មានមិនត្រូវបោះពុម្ពផ្សាយ ឬផ្សាយបន្តការមិនពិត ដែលជាការជេរប្រមាថ ការមើលងាយដល់ស្ថាប័នជាតិ ។ ការផ្សាយបែបនេះអាចត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពីពីរលាន(២.០០០.០០០)រៀល ទៅដប់លាន(១០.០០០.០០០)រៀល ។

**មាត្រា១៤.-**

សារព័ត៌មានមិនត្រូវបោះពុម្ពផ្សាយនូវអ្វីដែលប៉ះពាល់ដល់ប្រពៃណីល្អរបស់សង្គមជាតិ ជាអាទិ៍ :

-ពាក្យអសុរោះមិនគួរគប្បី ដូចជា អា មីង ជាដើម

-ពាក្យដែលពិពណ៌នាចំៗអំពីសកម្មភាពរួមភេទ

-រូបគំនូរ ឬរូបថតដែលបង្ហាញនូវកេរ្តិ៍ភេទ ឬរូបអាក្រាត លើកលែងតែទិសដៅសម្រាប់អប់រំចេញ

-រូបភាពដែលប្រមាថមើលងាយប្រៀបធៀបមនុស្សទៅនឹងសត្វតិរច្ឆាន ។

ការរំលោភទៅលើមាត្រានេះ អាចត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពីមួយលាន(១.០០០.០០០)រៀល ទៅប្រាំលាន(៥.០០០.០០០)រៀល ។

**មាត្រា១៥.-**

លើកលែងតែមានការអនុញ្ញាតពីតុលាការ សារព័ត៌មានពុំអាចផ្សាយដំណឹង រូបថត ឬគំនូរដែលអាចឱ្យអ្នកអានស្គាល់ឈ្មោះ និងអត្តសញ្ញាណនៃ :

-ភាគីក្នុងរឿងរដ្ឋប្បវេណីដែលទាក់ទងទៅនឹងបិតុភាព អាពាហ៍ពិពាហ៍ រឿងលែងលះប្តីប្រពន្ធ ឬរឿងអាណាព្យាបាលលើកុមារ ។

-យុវជនអាយុតិចជាងដប់ប្រាំបី(១៨)ឆ្នាំ ក្នុងរឿងវិវាទរដ្ឋប្បវេណី ឬព្រហ្មទណ្ឌ

-ស្ត្រីដែលទទួលរងគ្រោះដោយអំពើរំលោភលើរាងកាយ ឬអំពើចាប់បង្ខំសេពសន្ថវៈ ។

ក្នុងករណីដែលសាមីជន ឬអ្នកអាណាព្យាបាលយល់ព្រមជាលាយលក្ខណ៍អក្សរ សារព័ត៌មានអាចផ្សព្វផ្សាយរឿងនេះបាន លើកលែងតែការផ្សាយនេះនាំឱ្យប៉ះពាល់ដល់ការស៊ើបអង្កេតរបស់តុលាការ ។

បុគ្គលណាដែលត្រូវសារព័ត៌មានបំពានសិទ្ធិខាងលើនេះ មានសិទ្ធិប្តឹងទៅតុលាការ ដើម្បីទាមទារសំណងជំងឺចិត្ត ។ ការប្រព្រឹត្តល្មើសនឹងបទប្បញ្ញត្តិខាងលើនេះ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពីមួយលាន(១.០០០.០០០)រៀលទៅប្រាំលាន(៥.០០០.០០០)រៀល ។

**មាត្រា១៦.-**

ដំណឹងផ្សាយពាណិជ្ជកម្មអាចចាត់ទុកថា មានលក្ខណៈភូតកុហក បើការផ្សាយនោះមានន័យបំផ្លើសហួសហេតុអំពីគុណភាព ឬគុណសម្បត្តិផលិតផល ឬសេវាណាមួយបណ្តាលឱ្យអ្នកប្រើប្រាស់មានការភ័ន្តច្រឡំអំពីគុណភាព ឬគុណសម្បត្តិនោះ ។

ការផ្សាយពាណិជ្ជកម្មបៀបនេះត្រូវហាមឃាត់ ប៉ុន្តែសារព័ត៌មានដែលចុះផ្សាយដំណឹងភូតកុហកនេះ មិនមែនជាអ្នកទទួលខុសត្រូវចំពោះមុខច្បាប់ទេ លើកលែងតែសារព័ត៌មាននេះនៅតែបន្តផ្សាយដំណឹងនេះក្រោយពីបានទទួលការហាមប្រាមជាលាយលក្ខណ៍អក្សរពីតុលាការ ឬពីក្រសួងមានសមត្ថកិច្ចរួចហើយ ។

ផ្ទុយទៅវិញ អ្នកម្ចាស់ឃោសនាពាណិជ្ជកម្មជាអ្នកទទួលខុសត្រូវចំពោះមុខច្បាប់ និងចំពោះតុលាការ បើមានការប្តឹងផ្តល់អំពីបុគ្គល ឬសមាគមអ្នកប្រើប្រាស់ណាមួយដែលបានទទួលការខូចខាតប្រយោជន៍ បណ្តាលមកពីការផ្សាយពាណិជ្ជកម្មភូតកុហកនេះ ។

ការផ្សាយពាណិជ្ជកម្មភូតកុហកអាចត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពីមួយលាន(១.០០០.០០០)រៀលទៅប្រាំលាន(៥.០០០.០០០)រៀល ។

## ជំពូកទី៣
## ការប្រមូលផ្តុំ

**មាត្រា១៧.-**

បុគ្គលណាក៏ដោយ ទោះជារូបវន្តបុគ្គលក្តី ឬនីតិបុគ្គលក្តី មិនអាចធ្វើជាម្ចាស់ ឬជាអ្នកកាន់កាប់សារព័ត៌មានជាភាសាខ្មែរលើសពីពីរ(២)ឡើយនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា១៨.-**

ចំនួនសរុបទាំងអស់នៃសារព័ត៌មានជាភាសាខ្មែរ ដែលកាន់កាប់ដោយជនបរទេស មិនត្រូវឱ្យលើសពីម្ភៃ(២០)ភាគរយនៃចំនួនសារព័ត៌មានជាភាសាខ្មែរទាំងអស់ ដែលចេញផ្សាយនៅក្នុងព្រះរាជាណាចក្រកម្ពុជាឡើយ ។

សារព័ត៌មានដែលកាន់កាប់ដោយជនបរទេសដែលបានអនុញ្ញាតឱ្យចេញផ្សាយរួចហើយ មិនអាចត្រូវបិទដោយមូលហេតុថយចុះចំនួនសរុបទាំងអស់នៃសារព័ត៌មានជាភាសាខ្មែរនោះទេ ។

## ជំពូកទី៤
## ការតម្កល់ទុក

**មាត្រា១៩.-**

និពន្ធនាយក ឬនាយកការផ្សាយត្រូវតម្កល់ទុកសារព័ត៌មានរាល់លេខរបស់ខ្លួនចំនួនពីរ(២)ច្បាប់នៅបណ្ណាល័យជាតិ និងប្រាំមួយ(៦)ច្បាប់ទៀតនៅក្រសួងព័ត៌មាន ។ ការតម្កល់ទុកនេះ ត្រូវធ្វើឡើងក្នុងរយៈពេលដប់ប្រាំ(១៥)ថ្ងៃ ចំពោះការបោះពុម្ពនៅភ្នំពេញ និងសែសិបប្រាំ(៤៥)ថ្ងៃនៅកន្លែងដទៃទៀត ដោយគិតពីកាលបរិច្ឆេទនៃការចេញផ្សាយ ។

ការប្រព្រឹត្តល្មើសនឹងបទប្បញ្ញត្តិខាងលើនេះ ត្រូវផ្តន្ទាទោសពិន័យជាអន្តរការណ៍ដោយក្រសួងព័ត៌មានជាប្រាក់ពីបីម៉ឺន(៣០.០០០)រៀល ទៅបីសែន(៣០០.០០០)រៀល ។

## ជំពូកទី៥
## អវសានបញ្ញត្តិ

**មាត្រា២០.-**

អំពើប្រព្រឹត្តរបស់និយោជក និពន្ធនាយក ឬអ្នកនិពន្ធអត្ថបទដែលរំលោភច្បាប់ព្រហ្មទណ្ឌ ត្រូវទទួលទោសតាមច្បាប់ព្រហ្មទណ្ឌ ។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ក៏គ្មានជនណាម្នាក់ត្រូវចាប់ចង ឬជាប់ពន្ធនាគារដោយសារការបញ្ចេញមតិឡើយ ។

**មាត្រា២១.-**

បទប្បញ្ញត្តិទាំងឡាយដែលមានពីមុនមក ហើយទាក់ទងនឹងសារព័ត៌មាន ត្រូវចាត់ទុកជានិរាករណ៍ ។

ធ្វើនៅរាជធានីភ្នំពេញ នៅថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ១៩៩៥
ក្នុងព្រះបរមនាមនិងតាមព្រះរាជបង្គាប់
**ប្រមុខរដ្ឋស្តីទី**
**ហត្ថលេខា**
**ជា ស៊ីម**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រីទី១**
**ព្រះហត្ថលេខា**
**នរោត្តម រណឫទ្ធិ**

**នាយករដ្ឋមន្ត្រីទី២**
**ហត្ថលេខា**
**ហ៊ុន សែន**

បានបង្គំទូលថ្វាយនិងជំរាបជូន
សម្តេចនាយករដ្ឋមន្ត្រីទី១ និង ទី២
**រដ្ឋមន្ត្រីក្រសួងព័ត៌មាន**
**ហត្ថលេខា**
**អៀង មូលី**

លេខ .....៤៨..ច.ល.
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ ១៩៩៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**
**ឈាវ តាន់**